ឆ្នោតក្នុងរយៈពេលបី (៣) ថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងពីគណៈកម្មការ ខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវសម្រេចលើបណ្តឹងតវ៉ាឬជំទាស់នេះ ក្នុងរយៈពេលប្រាំ ( ៥ ) ថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

-ក្នុងករណីដែលអ្នកប្តឹងតវ៉ាឬជំទាស់នៅពុំពេញចិត្តនឹងការសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ជននោះឬអ្នកតំណាងអាចប្តឹងតវ៉ាឬជំទាស់ជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលពីរ ( ២ ) ថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសម្រេចលើបណ្តឹងតវ៉ាឬជំទាស់នេះ ក្នុងរយៈពេលប្រាំ ( ៥ ) ថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

* * * *

## ព្រះរាជក្រម ជស/ រកម/ ០៤៩៨/ ០៦

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

* * * *

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/ ៩៤/ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ១០៩៤/ ៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ១០៩៤/ ៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ជស/ រកត/ ០៨៩៧/ ១៨៧ ចុះថ្ងៃទី ៧ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/ រកម / ១០៩៦/ ០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានឃើញព្រះរាជក្រមលេខ នស/ រកម /១២៩៧/ ០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំពីសម្តេចនាយករដ្ឋមន្ត្រីទី១ និងសម្តេចនាយករដ្ឋមន្ត្រីទី ២ និងអំពីទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ប្រកាសអោយប្រើ**

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៨ នាសម័យប្រជុំលើកទី ៨ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ច្បាប់

# ស្តីពី

# ការរៀបចំ និងប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

## ជំពូកទី ១

## ការរៀបចំក្រុមប្រឹក្សាធម្មនុញ្ញ

មាត្រា ១ .- ច្បាប់នេះមានគោលដៅបង្កើត និងកំណត់ការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញនិងច្បាប់ ពិនិត្យនិងសម្រេចអំពីវិវាទកម្មទាក់ទងនឹងការ បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

មាត្រា ២ .- ក្រុមប្រឹក្សាធម្មនុញ្ញជាស្ថាប័នឯករាជ្យនិងអព្យាក្រឹតក្នុងការបំពេញសមត្ថកិច្ចរបស់ខ្លួន ។ ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិក ៩រូប ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានអាណត្តិ ៩ ឆ្នាំ ។

មាត្រា ៣ .- សមាជិកទាំង ៩ រូប នៃក្រុមប្រឹក្សាធម្មនុញ្ញត្រូវជ្រើសរើសក្នុងចំណោមឥស្សរជនដែលមានសញ្ជាតិខ្មែរពីកំណើត មានអាយុយ៉ាងតិច ៤៥ ឆ្នាំ មានសញ្ញាបត្រចាប់ពីឧត្តមសិក្សាឡើងទៅខាងច្បាប់ ខាងរដ្ឋបាល ខាងការទូត ឬខាងសេដ្ឋកិច្ច ហើយដែលមានបទពិសោធន៍ក្នុងការងារយ៉ាងតិច ១៥ឆ្នាំ ។

សមាជិក នៃក្រុមប្រឹក្សាធម្មនុញ្ញ ៣រូប ត្រូវតែងតាំងដោយព្រះមហាក្សត្រ ៣រូប ត្រូវតែងតាំងដោយ ក្រុមប្រឹក្សានៃអង្គចៅក្រមហើយ ៣រូបទៀត ត្រូវតែងតាំងដោយរដ្ឋសភាតាមមតិភាគច្រើនដាច់ខាត នៃសមាជិកនៃរដ្ឋសភាទាំងមូល ។

ការជ្រើសតាំងដោយរដ្ឋសភាអាចធ្វើឡើងជាពីរលើកបាន ។

ក្នុងអាណត្តិទី ១ បើការបោះឆ្នោតលើកទី១ មិនបានទទួលមតិភាគច្រើនដាច់ខាតនោះ ត្រូវបោះឆ្នោតជាលើកទី២ ដោយយកអ្នកដែលបានទទួលសម្លេងច្រើនជាងគេចំនួនយ៉ាងច្រើន៥រូប មកបោះឆ្នោតឡើងវិញ ។ ការបោះឆ្នោតលើកទី២ នេះត្រូវយកតាមមតិភាគច្រើនដោយប្រៀប ។ អ្នកដែលទទួលបានសម្លេងច្រើនជាង គេត្រូវតែងតាំងសម្រាប់ ៩ឆ្នាំ អ្នកដែលទទួលបានសម្លេងបន្ទាប់ត្រូវតែងតាំងសម្រាប់ ៦ឆ្នាំ និងអ្នកដែលទទួល បានសម្លេងបន្ទាប់មកទៀតត្រូវតែងតាំងសម្រាប់ ៣ឆ្នាំ ។

ក្នុងអាណត្តិបន្តបន្ទាប់ បើការបោះឆ្នោតលើកទី ១ មិនបានទទួលមតិភាគច្រើនដាច់ខាតនោះ ត្រូវបោះឆ្នោតជាលើកទី២ ដោយយកអ្នកដែលបានទទួលសម្លេងច្រើនជាងគេចំនួន ២នាក់ មកបោះឆ្នោតឡើងវិញ ។ ការបោះឆ្នោតលើកទី២ នេះត្រូវយកតាមមតិភាគច្រើនដោយប្រៀប ។

ក្នុងករណីដែលបេក្ខជនទទួលបានសម្លេងស្មើគ្នានោះ ត្រូវយកអ្នកដែលមានអាយុច្រើនជាង គេ ។

បេក្ខជនម្នាក់ៗដែលនឹងត្រូវជ្រើសតាំងដោយរដ្ឋសភា ត្រូវមានហត្ថលេខាគាំទ្រជាមុន ពីសមាជិករដ្ឋសភាចំនួនមួយភាគដប់នៃសមាជិកទាំងមូល ។ សមាជិករដ្ឋសភា ១រូប មានសិទ្ធិគាំទ្របានតែបេក្ខជន ១រូបប៉ុណ្ណោះ ។

មាត្រា ៤ .- ក្នុងរយៈពេលបីឆ្នាំម្តង បីឆ្នាំម្តងសមាជិកចំនួន ៣រូប ត្រូវផ្លាស់ប្តូរនិងតែងតាំងជាថ្មីគឺ ១រូប តែងតាំងដោយព្រះមហាក្សត្រ ១រូប តែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង ១រូប ទៀតជ្រើសតាំងដោយរដ្ឋសភា ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានជ្រើសតាំងតាមការបោះឆ្នោតដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ រៀងរាល់៣ ឆ្នាំម្តង តាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ក្រោយពីសមាជិក ៣រូប ចូលកាន់តំណែង ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញចាស់អាចត្រូវបានជ្រើសតាំងជាថ្មីបាន ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានឋានៈ និងបុព្វសិទ្ធិស្មើ នឹងប្រធានរដ្ឋសភា ។

**សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានឋានៈ និងបុព្វសិទ្ធិស្មើ នឹងអនុប្រធានរដ្ឋសភា ។**

មាត្រា ៥._ មុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានវិសមិតភាពជាមួយនឹងមុខងារជាសមាជិករាជរដ្ឋាភិបាល សមាជិករដ្ឋសភា ប្រធាន អនុប្រធានគណបក្សនយោបាយ ប្រធាន អនុប្រធានសហជីព និងចៅក្រមក្នុងតំណែង ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មិនត្រូវបំពេញមុខតំណែងនិងមុខរបរផ្សេងទៀតនៅក្នុងអាណត្តិរបស់ខ្លួនឡើយ ។

អ្នកដែលបានតែងតាំងជាសមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញ មុនចូលកាន់តំណែងត្រូវសុំលាឈប់ជា បណ្តោះអាសន្នពីតំណែង ឬមុខរបរទាំងអស់ដែលបានចែងក្នុងវាក្យខ័ណ្ឌខាងលើ ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវជូនដំណឹងជាលាយលក្ខអក្សរទៅសមាជិកដែលនៅក្នុងមុខតំណែង និងមុខរបរនិងខាងលើអោយសុំលាឈប់ពីមុខតំណែង ឬមុខរបរនោះជាបន្ទាន់ ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសុំដកខ្លួនចេញពីរឿង ទាំងឡាយណាដែលផលប្រយោជន៍ផ្ទាល់ខ្លួនពាក់ព័ន្ធក្នុងរឿងនោះ ។ ការសុំដកខ្លួន ឬ ការតម្រូវអោយដកខ្លួន ត្រូវសម្រេចដោយក្រុមប្រឹក្សាធម្មនុញ្ញតាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ។

មាត្រា ៦ ._ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញនឹងត្រូវតែងតាំងជំនួយយ៉ាងយូរ ៣០ ថ្ងៃ មុនចប់អាណត្តិរបស់សមាជិកដែលត្រូវចេញពីតំណែង ។

ក្នុងករណីដែលមានការសុំលាឈប់ ឬការដកចេញពីតំណែង ឬមរណភាព សមាជិកថ្មីមកជំនួសត្រូវបានតែងតាំងដូចមានចែងក្នុងមាត្រា៤ ក្នុងរយៈពេល ៣០ថ្ងៃយ៉ាងយូរ ។

មាត្រា ៧ ._ មុនចូលកាន់តំណែងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញត្រូវធ្វើសច្ចាប្រណិធាន ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញត្រូវរក្សាការសំងាត់ក្នុងការពិភាក្សានិងការបោះឆ្នោតហើយមិនត្រូវបញ្ចេញយោបល់របស់ខ្លួនក្រៅអង្គប្រជុំទេ ។

មាត្រា ៨ ._ សមាជិកថ្មី នៃក្រុមប្រឹក្សាធម្មនុញ្ញដែលត្រូវបានតែងតាំង ជំនួសសមាជិកដែលត្រូវចាកចេញពីមុខតំណែងមុនចប់អាណត្តិធម្មតារបស់ខ្លួន មានអាណត្តិត្រឹមថិរវេលាដែលនៅសល់ប៉ុណ្ណោះ ។

ប៉ុន្តែបើថិរវេលានេះតិចជាង ៣ឆ្នាំ ឬស្មើនឹង ៣ឆ្នាំ នៅពេលចប់ថិរវេលានេះ សមាជិកនោះអាចត្រូវបានគេតែងតាំង ឬជ្រើសតាំងសម្រាប់អាណត្តិថ្មីមួយអាណត្តិទៀតបាន ។

មាត្រា ៩ ._ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញម្នាក់ៗ អាចសុំលាឈប់ពីតំណែងបាន ដោយគ្រាន់តែជូនដំណឹងជាលាយលក្ខអក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

មាត្រា ១០._ ក្រុមប្រឹក្សាធម្មនុញ្ញអាចដកចេញពីតំណែងនូវសមាជិកណាដែលបានរំលោភលើមាត្រា៥ និង ៧នៃច្បាប់នេះ ឬដែលមិនបានមកប្រជុំលើសពី៣ ដងជួនៗគ្នាដោយពុំបានជូនដំណឹងជាមុន ឬ ដែលមិនអាចបំពេញមុខ ងារជាទៀងទាត់បានដោយបាត់បង់សមត្ថភាពខាងបញ្ញា ឬរូបកាយជាអចិន្ត្រៃយ៍ ។

ការសម្រេចដកសមាជិកក្រុមប្រឹក្សាធម្មនុញ្ញណាមួយ ពីតំណែងតម្រូវអោយមានការយល់ព្រមពីសមាជិកចំនួនពីរភាគបីនៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញណា ដែលត្រូវបានតុលាការកាត់ទោសដាក់ពន្ធនាគារពីបទមជ្ឈិម ឬ ឧក្រិដ្ឋ ត្រូវដកចេញពីមុខតំណែងជាស្វ័យប្រវត្តិ ។

មាត្រា ១១.- សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមិនត្រូវទទួលខុសត្រូវខាងបទព្រហ្មទណ្ឌ ឬ រដ្ឋប្បវេណីណាមួយ ចំពោះការសម្រេចដែលបានធ្វើ នៅពេលដែលគេបំពេញភារកិច្ចជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញឡើយ ។

## ជំពូកទី ២

## ការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

### ផ្នែកទី ១

### បទប្បញ្ញត្តិរួម

មាត្រា ១២.- ក្រុមប្រឹក្សាធម្មនុញ្ញត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

បទបញ្ជាផ្ទៃក្នុងត្រូវអនុម័តដោយមតិភាគច្រើនពីរភាគបី នៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល ។

ក្រុមប្រឹក្សាធម្មនុញ្ញមានអគ្គលេខាធិការដ្ឋានមួយជាជំនួយការ ។

ការរៀបចំ និងការប្រព្រឹត្តិទៅនៃអគ្គលេខាធិការដ្ឋានត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ១៣.- ក្រុមប្រឹក្សាធម្មនុញ្ញមានថវិការបស់ខ្លួនដែលផ្តល់អោយដោយថវិកាជាតិ ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញជាអាណាប័កដើមខ្សែ ។

មាត្រា ១៤.- កិច្ចប្រជុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវកោះអញ្ជើញដោយប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ឬ ដោយសមាជិក ដែលមានអាយុច្រើនជាងគេ បើប្រធានមានធុរៈមិនអាចធ្វើបាន ។

កិច្ចប្រជុំនៃក្រុមប្រឹក្សាធម្មនុញ្ញអាចចាត់ទុកជាបានការ លុះត្រាតែមានសមាជិកចំនួន ៧រូប ចូលរួមប្រជុំ ។

### ផ្នែកទី ២

### សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញចំពោះធម្មនុញ្ញភាពនៃច្បាប់

មាត្រា ១៥.- ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែល អនុម័តដោយរដ្ឋសភា ក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ។

មាត្រា ១៦.- ច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុងរដ្ឋសភានិងវិសោធនកម្មនៃច្បាប់រៀបចំអង្គការ និង បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ក្រោយរដ្ឋសភាបានអនុម័ត ត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញដោយប្រធានរដ្ឋសភា ដើម្បីពិនិត្យ តើច្បាប់ទាំងនោះស្រប ឬ មិនស្រប នឹងរដ្ឋធម្មនុញ្ញ មុននឹងត្រូវបានប្រកាសអោយប្រើ ។

មាត្រា ១៧._ ព្រះមហាក្សត្រ ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី ឬ តំណាងរាស្ត្រចំនួនមួយភាគដប់អាចបញ្ជូនច្បាប់ផ្សេងទៀតដែលរដ្ឋសភាបានអនុម័តទៅជូនក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងប្រកាសអោយប្រើ ។

មាត្រា ១៨._ ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសអោយប្រើ ព្រះមហាក្សត្រ ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី ឬ តំណាងរាស្ត្រចំនួនមួយភាគដប់ ឬតុលាការអាចសុំអោយក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះបាន ។

ប្រជារាស្ត្រមានសិទ្ធិប្តឹងអំពីអធម្មនុញ្ញភាពនៃច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញបានតាមរយៈប្រធានរដ្ឋសភា ឬតំណាងរាស្ត្រដូចមានចែងក្នុងវាក្យខណ្ឌខាងលើ ។

មាត្រា ១៩._ បុគ្គលដែលជាប់ពាក់ព័ន្ធក្នុងរឿងក្តីណាមួយ ហើយរឿងក្តីនោះឡើងដល់តុលាការ បុគ្គលនោះអាចលើកអំពីអធម្មនុញ្ញភាពនូវបទប្បញ្ញត្តិណាមួយនៃច្បាប់ ឬ សេចក្តីសម្រេចរបស់ស្ថាប័ននានាដែលគេអះអាងថា ប៉ះពាល់ដល់សិទ្ធិសេរីភាពជាការវន្តណាមួយរបស់គេជូនតុលាការបាន ។

បើយល់ឃើញថា ការលើកឡើងនេះមានមូលដ្ឋានគ្រប់គ្រាន់តុលាការត្រូវលើកករណីនេះទៅតុលាការកំពូលក្នុងរយៈពេល ១០ថ្ងៃយ៉ាងយូរ ។

តុលាការកំពូលត្រូវចាត់ការពិនិត្យនិងប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ១៥ ថ្ងៃយ៉ាងយូរ បើតែតុលាការកំពូលយល់ឃើញថា ពាក្យប្តឹងតវ៉ានោះមិនអាចទទួលបាន ។

មាត្រា ២០._ បើក្រុមប្រឹក្សាធម្មនុញ្ញកំណត់ថាបទប្បញ្ញត្តិណាមួយនៃច្បាប់មិនស្របនឹងរដ្ឋធម្មនុញ្ញ ៖

ក- បើបទប្បញ្ញត្តិនោះមិនអាចបំបែកចេញពីអត្ថបទដែលនៅសល់បានទេ អត្ថបទច្បាប់ទាំងមូលមិនអាចយកទៅប្រកាសអោយប្រើ ឬ យកទៅអនុវត្តបានឡើយ ។

ខ-បើបទប្បញ្ញត្តិនោះអាចបំបែកចេញពីអត្ថបទដែលនៅសល់បាននោះមានតែបទប្បញ្ញត្តិដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញប៉ុណ្ណោះទេ ដែលមិនអាចយកទៅប្រកាសអោយប្រើ ឬយកទៅអនុវត្តបាន ។

មាត្រា ២១._ ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិអញ្ជើញជនណាម្នាក់ឬ ច្រើននាក់មកបំភ្លឺ ឬផ្តល់ឯកសារដែលពាក់ព័ន្ធបាន ។

បុគ្គលគ្រប់រូប ស្ថាប័នរដ្ឋ ឬឯកជនទាំងឡាយ ត្រូវគោរព និងប្រតិបត្តិតាមការអញ្ជើញ និងការស្នើសុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

មាត្រា ២២._ ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសម្រេចសេចក្តីជាលាយលក្ខណ៍អក្សរលើគ្រប់ករណីដែលត្រូវបានដាក់ជូនក្នុងរយៈពេល ៣០ ថ្ងៃ ។ ប្រសិនបើជាការប្រញាប់ រយៈពេលនេះត្រូវបន្ថយមកត្រឹម ៨ថ្ងៃ ។

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យពិចារណាលើធម្មនុញ្ញភាព ដោយផ្អែកលើសេចក្តីរាយការណ៍របស់សមាជិក ដែលប្រធានបានប្រគល់ភារកិច្ចអោយពិនិត្យរាយការណ៍ ។

ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចសេចក្តីមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ។ ក្នុងករណីដែលបែកសម្លេងជាពីរស្មើគ្នា សម្លេងរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញជាសម្លេងឧត្តមានុភាព ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបញ្ជាក់អំពីហេតុផល ។

មាត្រា ២៣._ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ គឺជាសេចក្តីសម្រេចពិចារ្ណាវគ្គ ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

មាត្រា ២៤._ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវផ្ញើថ្វាយព្រះមហាក្សត្រ ជូនប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី និងប្រធានតុលាការកំពូល និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

ប្រធានរដ្ឋសភា ត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះ ដល់សមាជិករដ្ឋសភាទាំងអស់ ។

នាយករដ្ឋមន្ត្រី ត្រូវជូនដំណឹងទៅសមាជិករាជរដ្ឋាភិបាលទាំងអស់ ។

ប្រធានតុលាការកំពូលត្រូវជូនដំណឹងដល់តុលាការសាមី ។

## ផ្នែកទី ៣

## សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញចំពោះការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

មាត្រា ២៥ ._ ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចអំពីវិវាទកម្មទាក់ទង នឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

មាត្រា ២៦ ._ ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេច :

១-លើបណ្តឹងតវ៉ារបស់គណបក្សនយោបាយ ឬ របស់បេក្ខជនប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធលើការតវ៉ាពីបក្ខភាព ឬសម្រេចបដិសេធលើការតវ៉ាពីបញ្ជីរាយនាមបេក្ខជន ។ ការប្តឹងនេះត្រូវធ្វើឡើងក្នុងរយៈពេល ៥ថ្ងៃយ៉ាងយូរក្រោយពីបានទទួល លិខិតជូនដំណឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

២-លើបណ្តឹងតវ៉ារបស់បុគ្គលប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធការតវ៉ាសុំចុះឈ្មោះបោះឆ្នោត ។ ការប្តឹងនេះត្រូវធ្វើឡើង ក្នុងរយៈពេល ៥ថ្ងៃ យ៉ាងយូរ ក្រោយពីបានទទួលលិខិតជូនដំណឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

៣-លើបណ្តឹងតវ៉ារបស់បុគ្គល ឬអ្នកតំណាងប្តឹងមិនសុខចិត្ត នឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធអំពីការលុបឈ្មោះ ឬអំពីការជំទាស់នឹងការចុះឈ្មោះ ឬអំពីការរក្សាទុកឈ្មោះក្នុងបញ្ជីបោះឆ្នោតនូវបុគ្គលណាម្នាក់ដែលគេយល់ឃើញថា មានហេតុណាមិនត្រឹមត្រូវតាមលក្ខខណ្ឌនៃច្បាប់បោះឆ្នោត ។ ការប្តឹងនេះត្រូវធ្វើឡើងក្នុងរយៈពេល ៥ថ្ងៃយ៉ាងយូរក្រោយពីបានទទួលលិខិត ជូនដំណឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចករណីខាងលើក្នុងរយៈ ១០ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្តឹង ។

៤-លើបណ្តឹងតវ៉ារបស់គណបក្សនយោបាយពីការមិនព្រមចុះបញ្ជីគណបក្សនយោបាយ ។ បណ្តឹងនេះត្រូវធ្វើឡើងក្នុងរយៈពេល ៥ ថ្ងៃយ៉ាងយូរ ក្រោយពីបានទទួលលិខិតជូនដំណឹងរបស់ក្រសួងមហាផ្ទៃ ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចការណ៍នេះក្នុងរយៈពេល ៣០ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្តឹងរបស់គណបក្សនយោបាយ ។

មាត្រា ២៧._ ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យនិងសម្រេច :

១-លើបណ្តឹងតវ៉ាដោយផ្ទាល់អំពីលទ្ធផលនៃការបោះឆ្នោតដែលបុគ្គលឬគណបក្ស នយោបាយដែលបានឈរឈ្មោះបោះឆ្នោតមិនសុខចិត្ត នឹងលទ្ធផលនៃការបោះឆ្នោត ។ បណ្តឹងនេះត្រូវធ្វើឡើងក្នុងរយៈពេល ៧២ ម៉ោងយ៉ាងយូរ បន្ទាប់ពីការប្រកាសលទ្ធផលបណ្តោះអាសន្ន ។

២-លើបណ្តឹងតវ៉ារបស់បុគ្គលឬគណបក្សដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធការតវ៉ាអំពីលទ្ធផលនៃការបោះ ។ ឆ្នោតការប្តឹងតវ៉ានេះត្រូវធ្វើ ឡើងក្នុងរយៈពេល ៤៨ ម៉ោងយ៉ាងយូរ ក្រោយពីបានទទួលលិខិតជូនដំណឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចការណ៍ខាងលើក្នុងរយៈពេល ២០ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្តឹង ។

មាត្រា ២៨._ បុគ្គលណា ឬគណបក្សនយោបាយណាដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ មិនសុខចិត្តនឹងលទ្ធផលនៃការបោះឆ្នោតត្រូវធ្វើពាក្យប្តឹងជាលាយលក្ខ-អក្សរជូនទៅក្រុមប្រឹក្សាធម្មនុញ្ញ ។ ពាក្យសុំនេះត្រូវបញ្ជាក់ :

១-ឈ្មោះបុគ្គល ឬឈ្មោះគណបក្សនយោបាយ ដែលជាអ្នកប្តឹងតវ៉ា

២-ឋានៈតាមផ្លូវច្បាប់របស់អ្នកប្តឹងតវ៉ា ( ជាអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ឬ ជាបេក្ខជន ឬ ជាតំណាងគណបក្សនយោបាយ ។

៣-ឈ្មោះមណ្ឌលបោះឆ្នោតដែលមានការប្តឹងតវ៉ា

៤-ឈ្មោះបុគ្គល ឬគណបក្សនយោបាយដែលត្រូវបានគេប្រកាសថាជាប់ឆ្នោតហើយដែលគេប្តឹងតវ៉ា។

៥-គ្រប់ឯកសារ ឬភស្តុតាងសម្រាប់គាំទ្រការសុំបដិសេធ ។

ក្រុមប្រឹក្សាធម្មនុញ្ញផ្អែកតាមឆន្ទានុសិទ្ធិរបស់ខ្លួនអាចទុកពេល ៥ថ្ងៃអោយបុគ្គល ឬគណបក្សនយោបាយដែលជាអ្នកប្តឹងដើម្បីផ្តល់ភស្តុតាង ។

ក្រុមប្រឹក្សាធម្មនុញ្ញអាចសម្រេចមិនធ្វើការស៊ើបអង្កេតលើបណ្តឹងណាមួយ បើបណ្តឹងនោះមិនបំពេញលក្ខខណ្ឌកំណត់ក្នុងមាត្រានេះ ។

គ្រប់ការណ៍ទាំងអស់ដែលប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញមិនតម្រូវអោយបង់ប្រាក់ទេ ។

**មាត្រា ២៩.**_ ពាក្យបណ្តឹងតវ៉ាគ្មានអានុភាពផ្អាកការអនុវត្តន៍ទេ ។ ប៉ុន្តែក្នុងពេលរង់ចាំសេចក្តីសម្រេចស្ថាពរ ក្រុមប្រឹក្សាធម្មនុញ្ញ បើសិនឃើញថាចាំបាច់អាចចេញបញ្ជាមួយ ដើម្បីផ្អាកជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រណាម្នាក់ ឬគណបក្សនយោបាយណាមួយដែលគេប្តឹងតវ៉ាបាន ។ បញ្ជានេះនឹងត្រូវបញ្ចប់អានុភាពនៅពេលដែលក្រុមប្រឹក្សាធម្មនុញ្ញចេញសេចក្តីសម្រេចជាស្ថាពរ ។

**មាត្រា ៣០.**_ ដើម្បីស្រាវជ្រាវស៊ើបអង្កេត អំពីវិវាទកម្មទាក់ទងទៅនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ក្រុមប្រឹក្សាធម្មនុញ្ញចែកចេញជា ៣ក្រុម ។ ក្រុមនីមួយៗមានសមាជិក ៣រូប ដែល ១រូប ជាសមាជិកតែងតាំង ដោយព្រះមហាក្សត្រ ១រូប ជាសមាជិកជ្រើសតាំងដោយរដ្ឋសភានិង ១ រូបទៀតជាសមាជិកតែងតាំងដោយឧត្តម ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ សមាជិកក្នុងក្រុមទាំង ៣ នេះត្រូវជ្រើសរើសដោយវិធីចាប់ឆ្នោតក្រោមអធិបតីភាពនៃប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។

**មាត្រា ៣១.**_ ក្រោយពីបានទទួលពាក្យបណ្តឹង ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវប្រគល់សិទ្ធិទៅអោយក្រុមណាមួយទទួលខុសត្រូវធ្វើការស៊ើបអង្កេត ។ ក្រុមនោះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់ដល់អ្នកប្តឹងតវ៉ា និងដល់ជន ឬគណបក្សដែលត្រូវគេប្តឹងតវ៉ា ដោយកំណត់រយៈពេល ១០ថ្ងៃ ដើម្បីពិនិត្យលើសេចក្តីប្តឹងតវ៉ា និងភស្តុតាង ដែលភាគីបានផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ និងដើម្បីផ្តល់លិខិតឆ្លើយតបជាលាយលក្ខណ៍អក្សរ ។

**មាត្រា ៣២.**_ ក្រោយពីបានទទួលលិខិតឆ្លើយតបខាងលើនេះ ឬក្រោយផុតកំណត់រយៈពេល ១០ថ្ងៃ និងក្រោយធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ ហើយក្រុមដែលទទួលបន្ទុកត្រូវដាក់លទ្ធផលនៃការស៊ើបអង្កេតព្រមទាំងយោបល់របស់ក្រុមនេះ ជូនក្រុមប្រឹក្សាធម្មនុញ្ញពេញអង្គ ។ ក្រុមប្រឹក្សាធម្មនុញ្ញអាចអោយធ្វើការស៊ើបអង្កេតបន្ថែមទៀត ហើយអាចស្តាប់អ្នកប្តឹងតវ៉ានិង អ្នកដែលត្រូវគេប្តឹងតវ៉ាដោយផ្ទាល់បាន ។

**មាត្រា ៣៣.**_ ក្នុងពេលធ្វើការស៊ើបអង្កេត ក្រុមប្រឹក្សាធម្មនុញ្ញឬក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញអាចធ្វើការសាកសួរលើគ្រប់បញ្ហាទាំងអស់ទាក់ទងឯកសារនិងព្រឹត្តិការណ៍ផ្សេងៗ និង កោះអញ្ជើញជនទាំងឡាយដែលពាក់ព័ន្ធក្នុងការបោះឆ្នោត ។

ក្រុមប្រឹក្សាធម្មនុញ្ញឬក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញអាចចាត់តាំងបុគ្គលិករបស់ខ្លួន ឬបុគ្គលផ្សេងទៀត អោយជួយក្នុងការស៊ើបអង្កេត ជាពិសេសនៅពេលទទួលចម្លើយរបស់សាក្សីដែលបានធ្វើសច្ចាប្រណិធានហើយ ។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃចម្លើយរបស់សាក្សីត្រូវតម្កល់ទុកសម្រាប់ភាគីទាំងអស់ ។ បើអ្នកស៊ើបអង្កេតឬសមាជិកក្នុងក្រុមបានជ្រាបដឹងថា សាក្សីមានការភ័យខ្លាចគេធ្វើបាប សាក្សីនោះត្រូវរក្សាទុកជា សម្ងាត់មិនអោយគេដឹងទាំងអស់ក្រៅពីក្រុមប្រឹក្សាធម្មនុញ្ញ ដោយដឹងតែអំពីខ្លឹមសារនៃចម្លើយប៉ុណ្ណោះ ។

មាត្រា ៣៤._ ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចសេចក្ដីក្នុងករណីដែលមានការតវ៉ា អំពីនីត្យានុកូលភាពនៃការបោះឆ្នោតអំពីភាពអាចជ្រើសតាំងបាននៃបេក្ខជនសម្រាប់បោះឆ្នោត និងភាពអាចជ្រើសតាំងបាននៃបេក្ខជន ដែលប្រកាសថាជាប់ឆ្នោត ។

ក្រុមប្រឹក្សាធម្មនុញ្ញអាចយល់ស្របឬមិនយល់ស្របតាមសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចប្រកាសមោឃភាពនៃការបោះឆ្នោតដែលគេប្ដឹងតវ៉ា ឬប្រកាសថាបេក្ខជនជាប់ឆ្នោត ដោយត្រឹមត្រូវ ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចសេចក្ដីមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ។ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបញ្ជាក់អំពីហេតុផល ។

សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្ដីសម្រេចស្ថាពរបិទផ្លូវតវ៉ា ។

សេចក្ដីសម្រេចនេះត្រូវថ្វាយព្រះមហាក្សត្រ បញ្ជូនទៅរដ្ឋសភា និងរាជរដ្ឋាភិបាលហើយត្រូវចុះក្នុងរាជកិច្ច ។

មាត្រា ៣៥._ ក្រុមប្រឹក្សាធម្មនុញ្ញ មានសិទ្ធិបញ្ជូនបណ្ដឹងដែលមិនចូលក្នុងសមត្ថកិច្ចរបស់ខ្លួនទៅអង្គការ មានសមត្ថកិច្ច ។

## ជំពូកទី ៣

## ទោសប្បញ្ញត្តិ

មាត្រា ៣៦._ ជនណាដែលមានពិរុទ្ធបានធ្វើជាសាក្សីមុសាវាទ ឬធ្វើការក្លែងបន្លំទៅលើសាក្សីក្នុងក្របខ័ណ្ឌ នៃការអង្កេតស៊ើបសួររបស់ក្រុមប្រឹក្សាធម្មនុញ្ញ ឬ ជនណាដែលមិនព្រមគោរពតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ឬរាំងខ្ទប់កិច្ចប្រតិបត្តិការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវផ្ដន្ទាទោស ដាក់ពន្ធនាគារពី ១ខែដល់ ១ឆ្នាំ និង ត្រូវពិន័យជាប្រាក់ពីដប់ម៉ឺន (១០០.០០០ ) រៀលដល់ហុកសិបម៉ឺន ( ៦០០.០០០ )រៀល ឬផ្ដន្ទាទោសណាមួយក្នុងចំណោមទោសទាំងពីរ ។

មាត្រា ៣៧._ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះត្រូវផ្ដន្ទាទោសខាងវិន័យ ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។ វិន័យនេះត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ធម្មនុញ្ញ ។

## ជំពូកទី ៤

## អន្តរប្បញ្ញត្តិ

មាត្រា ៣៨._ ក្នុងអាណត្តិទី១ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវមានសមាជិក ៣រូប តែងតាំងសម្រាប់រយៈពេល ៣ឆ្នាំ ៣រូប តែងតាំងសម្រាប់រយៈពេល ៦ ឆ្នាំ និង ៣ រូប ទៀតតែងតាំងសម្រាប់រយៈពេល ៩ ឆ្នាំ ។

ព្រះមហាក្សត្រទ្រង់តែងតាំងសមាជិក ១រូប សម្រាប់ ៣ឆ្នាំ ១រូប សម្រាប់ ៦ឆ្នាំ និង ១រូបទៀត សម្រាប់ ៩ ឆ្នាំ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវតែងតាំងសមាជិក១រូប ១រូបសម្រាប់ ៣ឆ្នាំ ១រូបទៀតសម្រាប់ ៦ឆ្នាំ និង១រូបទៀតសម្រាប់ ៩ ឆ្នាំ ។

រដ្ឋសភាត្រូវជ្រើសតាំងសមាជិក ១រូប សម្រាប់ ៣ឆ្នាំ ១រូប សម្រាប់ ៦ឆ្នាំ និង ១រូប ទៀតសម្រាប់ ៩ ឆ្នាំ ។

មាត្រា ៣៩._ ការកោះប្រជុំលើកទី ១ របស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវធ្វើឡើងក្នុងរយៈពេល ៧ ថ្ងៃ យ៉ាងយូរ បន្ទាប់ពីចេញព្រះរាជក្រឹត្យតែងតាំងសមាជិក ។ ការកោះប្រជុំនិងការដឹកនាំអង្គប្រជុំលើកទី ១ នេះត្រូវធ្វើឡើងដោយ សមាជិកដែលមានអាយុច្រើនជាងគេដែលមានវត្តមាន ដើម្បីជ្រើសតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

មាត្រា ៤០._ បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤១._ ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ១៩៩៩

ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជា

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

# ២- ក្រឹត្យ

## ក្រឹត្យ ជស/រកត/០៣៩៨/១១៩

## ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា

******

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-យោងតាមសំណូមពរចាំបាច់នៃការងារ

**បង្គាប់**

មាត្រា ១ ._ តែងតាំងឯកឧត្តមវេជ្ជបណ្ឌិត ថៃ ហ្វា ជាទីប្រឹក្សាផ្ទាល់របស់សម្តេច **ជា ស៊ីម** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

មាត្រា ២ ._ អគ្គលេខាធិការដ្ឋានរដ្ឋសភា ខុទ្ទកាល័យផ្ទាល់ប្រធានរដ្ឋសភា និង សាមីជនត្រូវប្រតិបត្តិអោយបានសំរេចតាមក្រឹត្យនេះ ។

មាត្រា ៣ ._ ក្រឹត្យនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៩

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

******

# ក្រឹត្យ ជស/រកត/០៣៩៩/១២០

## ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា

******

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-យោងតាមសំណូមពរចាំបាច់នៃការងារ

**បង្គាប់**

មាត្រា ១ ._ តែងតាំងឯកឧត្តម **សូ ជុនឃួរ** ជាទីប្រឹក្សាផ្ទាល់របស់សម្តេច **ជា ស៊ីម** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជាទទួលបន្ទុកការងារដឹកជញ្ជូនសាធារណការ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

មាត្រា ២ ._ អគ្គលេខាធិការដ្ឋានរដ្ឋសភា ខុទ្ទកាល័យផ្ទាល់ប្រធានរដ្ឋសភា និង សាមីជនត្រូវប្រតិបត្តិអោយបានសំរេចតាមក្រឹត្យនេះ ។

មាត្រា ៣ ._ ក្រឹត្យនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

ភ្នំពេញ , ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៩៩

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

## ក្រឹត្យ ជស / រកត / ០៤៩៩ / ១២១

### ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា

******

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-យោងតាមសំណូមពរចាំបាច់នៃការងារ

**បង្គាប់**

មាត្រា ១ ._ តែងតាំងឯកឧត្តមឧត្តមសេនីយ៍ ហ៊ត់លីរុន ស្ពាជាទី ជាទីប្រឹក្សាផ្ទាល់របស់សម្តេច ជា ស៊ីម ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបន្ទុកការងារសន្តិសុខមានឋានៈស្មើអនុរដ្ឋលេខាធិការបន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ ._ អគ្គលេខាធិការដ្ឋានរដ្ឋសភា ខុទ្ទកាល័យផ្ទាល់ប្រធានរដ្ឋសភា និង សាមីជនត្រូវប្រតិបត្តិអោយបានសំរេចតាមក្រឹត្យនេះ ។

មាត្រា ៣ ._ ក្រឹត្យនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

ភ្នំពេញ , ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ ១៩៩៩

ប្រមុខរដ្ឋស្តីទី

ប្រធានរដ្ឋសភា

ជា ស៊ីម

******

## ក្រឹត្យ ជស / រកត / ០៤៩៩ / ១២២

**យើង**

**ព្រះបាទសម្តេចព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

******

-បានទ្រង់ឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់ឃើញ [illegible] ក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-តាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី២ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៨

**ត្រាស់បង្គាប់**

មាត្រា ១ ._ បន្តអាណត្តិមូលនិធិសង្គម នៃព្រះរាជាណាចក្រកម្ពុជា ដែលមានអក្សរកាត់ថា "ម.ស.រ.ក" ចំនួនប្រាំឆ្នាំ ( ៥ ឆ្នាំ ) បន្តទៀត ដោយគិតចាប់តាំងពីថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩ រហូតដល់ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៤ ។

មាត្រា ២ ._ ការរៀបចំ និង ការប្រព្រឹត្តទៅនៃមូលនិធិសង្គម " ម.ស.រ.ក "ត្រូវបានកំណត់ដោយលក្ខន្តិកៈរបស់ " ម.ស.រ.ក " ដែលភ្ជាប់ក្នុងឧបសម្ព័ន្ធ ។

មាត្រា ៣ ._ នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ ._ ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់តាំងពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ភ្នំពេញ , ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៩៨
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខស្ដីទី
ហត្ថលេខា
ជា ស៊ីម

******

**ព្រះរាជក្រឹត្យ ជស / រកត / ០៤៩៨ / ១២៤**

**យើង**

**ព្រះបាទសម្ដេចព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

******

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាព នៃរាជរដ្ឋាភិបាលកម្ពុជា

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី២ រដ្ឋមន្ត្រីក្រសួងការពារជាតិ

**.ត្រាស់បង្គាប់**

មាត្រា ១ ._ ត្រូវបានតម្លើង ប្រគល់ឋានន្តរសក្តិកិត្តិយស នាយទាហានជាន់ខ្ពស់ ក្នុងកងយោធពល ខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

**ក_ តម្លើងឋានន្តរសក្តិ ជាឧត្តមសេនីយ៍ត្រី**

-លោកវរសេនីយ៍ឯក កែវ តាំ អត្តលេខ ០០០២៣២ នាយករងអធិការកិច្ច បច្ចុប្បន្នជានាយក នាយកដ្ឋានអធិការកិច្ច ។

**ខ_ ប្រគល់ឋានន្តរសក្តិ ជាឧត្តមសេនីយ៍ត្រី**

-លោក ស៊ូ សុខៈ ទីប្រឹក្សាក្រសួងការពារជាតិ

មាត្រា ២ ._ នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

******

## ព្រះរាជក្រឹត្យ ជស / រកត / ០៤៩៨ / ១២៥

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

******

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពនៃរាជរដ្ឋាភិបាលកម្ពុជា

-តាមសំណើរបស់ នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២ និងរដ្ឋមន្ត្រីក្រសួងការពារជាតិ

**ត្រាស់បង្គាប់**

**មាត្រា ១ ._** ត្រូវបានតម្លើង ឋានន្តរស័ក្តិ និងតែងតាំងផ្លាស់ប្តូរមុខងារនាយទាហានជាន់ខ្ពស់ ក្នុងកងយោធពលខេមរភូមិន្ទដែលមានរាយនាមដូចខាងក្រោម ៖

**ក_ ថ្នាក់ឧត្តមសេនីយ៍ទោ**

-លោកឧត្តមសេនីយ៍ត្រី **សេនា ស័ក្តិ** អត្តលេខ ០០០០៦៩ នាយកខុទ្ទកាល័យយោធា បច្ចុប្បន្នជានាយកទីចាត់ការការងារគណនេយ្យ អគ្គបញ្ជាការដ្ឋាន

**ខ_ ថ្នាក់ឧត្តមសេនីយ៍ត្រី**

-លោកវរសេនីយ៍ឯក **សំ ចណ្ណថន** អត្តលេខ ០០០២០៥ នាយករង ខុទ្ទកាល័យ យោធា បច្ចុប្បន្នជា នាយកខុទ្ទកាល័យយោធា ក្រសួងការពារជាតិ ។

**មាត្រា ២ ._** នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

**មាត្រា ៣ ._** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៩

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

******

# II- រាជរដ្ឋាភិបាល

## ១_ អនុក្រឹត្យ

**អនុក្រឹត្យលេខ ៩២ អនក្រ.តត**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

******

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២

**សំរេច**

**មាត្រា ១ .-** តែងតាំងលោក នុត ប៊ុតិណ្ណារ ជាសមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រីទី២ ឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ២ .-** សាលាបរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ខុទ្ទកាល័យសម្តេចនាយក រដ្ឋមន្ត្រីទី២ គ្រប់ក្រសួង គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះតាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

**អ៊ឹង ហួត ហ៊ុន សែន**

****

## អនុក្រឹត្យលេខ ៩៣ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

******

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើ [illegible] គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ [illegible] / រកត / ០៨៩៧ / ១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ១៩៩៧. **ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល**

-តាមសំណើរបស់ អភិបាលខេត្តកំពង់ធំ

**សំរេច**

មាត្រា ១ .- ត្រូវបានប្រគល់មេដាយមាសស្ថាបនាជាតិជូនឯកឧត្តម ខួន ញ៉ិល អ្នកតំណាងរាស្ត្រ សមាជិកសភាមណ្ឌលកំពង់ធំ បានបរិច្ចាគថវិកាផ្ទាល់ខ្លួន ជួយកសាងព្រះវិហារ វត្តត្រពាំងជ្រៃ ស្រុកបារាយណ៍ កុដិថ្មីសាលារៀន ផ្លូវថ្នល់ អស់ទឹកប្រាក់ចំនួន ១៤៨.៥០០ ដុល្លារអាមេរិក ។

មាត្រា ២ .- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាល ខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ឹង ហួត ហ៊ុន សែន

******

## អនុក្រឹត្យលេខ ៩៨ អនក្រ.តត
## ស្តីពីការបំពាក់ងារនូវសក្តិនាយនគរបាលជាតិ

******

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយក រដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើជាផ្លូវការនូវច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើជាផ្លូវការ នូវច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញក្រឹត្យ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំសញ្ញា និងរូបភាព ឋានន្តរសក្តិនគរបាលជាតិកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

មាត្រា ១ ._ ត្រូវបានបំពាក់ឋានន្តរសក្តិ ថ្នាក់វរសេនីយ៍ឯកជូនលោក ឌី ឌុង អនុប្រធាននាយកដ្ឋាន សរណ្ឋាប់ ឆ្មាប់ ។

មាត្រា ២ ._ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋ-កិច្ចនិង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង និងស្ថាប័នពាក់ព័ន្ធ និងលោក ឌី ឌុង ត្រូវអនុវត្តតាម អនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

**អ៊ឹង ហួត** **ហ៊ុន សែន**

******

**អនុក្រឹត្យលេខ ៩៥ អនក្រ.តត**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

******

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១០៩៤ / ៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ ជស / រកត / ០៨៩៧ / ១៥៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-យោងតាមសំណូមពរការងារចាំបាច់

**សំរេច**

មាត្រា ១ ._ តែងតាំងលោក **ញៀម សុខារ័ត្ន** ជាប្រធាននាយកដ្ឋាន ស្រាវជ្រាវ និងត្រួតពិនិត្យនៃអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

មាត្រា ២ ._ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គលេខា **ធិការនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រដ្ឋលេខាធិការនៃរដ្ឋលេខាធិ ការដ្ឋានមុខងារ**

សាធារណៈ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ុង ហួត ហ៊ុន សែន

******

# អនុក្រឹត្យលេខ ៩៦ អនក្រ.តត
# ស្តីពីការតែងតាំងមន្ត្រីរាជការ

******

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១០៩៤ / ៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ ជស / រកត / ០៨៩៧ / ១៩៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-យោងតាមសំណូមពរការងារចាំបាច់

## សំរេច

**មាត្រា ១ .-** តែងតាំងលោក **ឈឹម ផាទីន** ជាប្រធាននាយកដ្ឋាន នីតិកម្ម អប់រំ និងបង្ការការពារ នៃអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**មាត្រា ២ .-** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្ត អនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ុង ហួត ហ៊ុន សែន

## អនុក្រឹត្យលេខ ៩៧ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

******

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

-បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ០៨៩៧ / ១៥៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

-តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

## សំរេច

**មាត្រា ១ ._** ត្រូវបានតែងតាំងអស់លោកចំនួន ០៨ រូប ដូចមានរាយនាមខាងក្រោម ៖

១_លោក សេង ទារិទ្ធី ជាប្រធាននាយកដ្ឋាន នាយកដ្ឋានរដ្ឋបាល បុគ្គលិក

២_លោក ម៉ែល សុខុម ជាប្រធាននាយកដ្ឋាន នាយកដ្ឋានផ្គត់ផ្គង់ ហិរញ្ញវត្ថុ

៣_លោក កែវ ស៊ីវន ជាប្រធាននាយកដ្ឋាន នាយកដ្ឋានប្រតិបត្តិការសុវត្ថិភាពហោះហើរ

៤_លោក ពាង សារី ជាប្រធាននាយកដ្ឋាន នាយកដ្ឋានវិស្វកម្មអេឡិចត្រូនិក

៥_លោក សុខ ពុធធឿន ជាប្រធាននាយកដ្ឋាន នាយកដ្ឋានវិស្វកម្មអាកាសយានដ្ឋាន

៦_លោក រំចេក សុទារី ជាប្រធាននាយកដ្ឋាន នាយកដ្ឋានដឹកជញ្ជូនផ្លូវអាកាស

៧_លោក សិទ្ធ សាកល ជាប្រធាននាយកដ្ឋាន នាយកដ្ឋានសន្តិសុខ

៨_លោក ស៊ិន ចាន់សេរីវុឌ្ឍ ជាប្រធាននាយកដ្ឋាន នាយកដ្ឋានផែនការនិងពិនិត្យ

មាត្រា ២ ._ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង សាមីខ្លួនដូចមានចែងក្នុងមាត្រា១ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ពេញលេខា និងត្រា

អ៊ុង ហួត ហ៊ុន សែន

******

## III- ការងារបណ្ដាក្រសួង

### ១_ ទីស្ដីការគណៈរដ្ឋមន្ត្រី

### ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៨

### ប្រកាសលេខ ៣១ ប្រក

### ស្ដីពីការតែងតាំងមន្ត្រីរាជការ

******

### សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ ព្រះមហាក្សត្រ. នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញច្បាប់ស្ដីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤

-យោងតាមការចាំបាច់

**សំរេច**

**ប្រការ ១ :** តែងតាំងលោក **យន់ សុគន្ធ** ជាជំនួយការឯកឧត្តមនាយកខុទ្ទកាល័យ នាយករដ្ឋមន្ត្រីទី១ ដោយមានឋានៈស្មើនឹង **អនុប្រធាននាយកដ្ឋាន** ពេលបំពេញមុខការ ។

**ប្រការ ២ :** ប្រធាននាយកដ្ឋានបុគ្គលិក នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី១ ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ស្តីទី

**សុខ អាន** **សោខី តាន់**

******

## ២- ទីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៩៨

**ប្រកាសលេខ ១៨៨ សហវ.ឃ**

**ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ**

**ប្រចាំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ២**

******

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យ នស / រកត / ១០៩៤ / ៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស / រកត / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

៖

-បានឃើញព្រះរាជក្រឹត្យ ជស / រកត / ០៨៩៧ / ១៥៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ / នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

-បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័តរាជធានីភ្នំពេញ និងអង្គភាពសាធារណៈរដ្ឋបាល

-បានឃើញច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស / រកម / ១២៩៧ / ០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧

-បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ០១៩៨ / ០៥២ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសតាំងតំណាង រាស្ត្រនីតិកាលទី ២

-បានឃើញច្បាប់ស្តីពីការបង្កើតគណនីពិសេសរបស់ធនាគារជាតិសំរាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស / រកម / ០៣៩៨ / ០៤ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩៨

-យោងលិខិតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី២ លេខ ០៣ / ១២១ / ៩៨ គជប ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៩៨

-យោងតាមតំរូវការចាំបាច់របស់ក្រសួង

**សំរេច**

ប្រការ ១ : ត្រូវបានតែងតាំងលោក **សាម មុិនហេង** ប្រធាននាយកដ្ឋានហិរញ្ញកិច្ច ជាមន្ត្រីត្រួតពិនិត្យ ហិរញ្ញវត្ថុប្រចាំគណៈកម្មាធិការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី២ បន្ថែមលើភារកិច្ចបច្ចុប្បន្ន ។

ប្រការ ២ : អគ្គនាយក នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធានធនាគារជាតិប្រធាននាយកដ្ឋានថវិកា ប្រធាននាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស និង អង្គភាពពាក់ពន្ធព្រមទាំងលោក **សាម មុិនហេង** ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**គាត ឈន់**

******

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៨

**ប្រកាសលេខ ០៥៨ សហវ.ប្រក.ប**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

******

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រឹត្យ នស / រកត / ១០៩៨ / ៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ៨១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

-បានឃើញព្រះរាជក្រឹត្យ ជស / រកត / ០៨៩៧ / ១៥៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៤

-បានពិនិត្យលិខិតលេខ ២២៩២.រតន ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ១៩៩៥ របស់រតនាគារជាតិ

-បានឃើញការចាំបាច់របស់ក្រសួង

**សំរេច**

**ប្រការ ១ :** ត្រូវបានតែងតាំងលោក **ឱុច ហឿន** ប្រធានអធិការកិច្ចរតនាគារជាតិ ជាស្នងការគណនីប្រចាំអាជ្ញាធរអប្សរា បន្ថែមលើ ភារកិច្ចបច្ចុប្បន្នជំនួសលោក **ម៉ុង ស៊ីម** ដែលបច្ចុប្បន្នទទួលភារកិច្ចថ្មី ។

**ប្រការ ២ :** អគ្គនាយក នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធានរតនាគារជាតិ និងអង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចក្នុងប្រការខាងលើ ត្រូវទទួលបន្ទុកអនុវត្ត តាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា និងត្រា

**គាត ឈន់**

## ៣-នីតិការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

### ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៩៨

ប្រកាសលេខ ២៧៧ ឧក.ប្រក

* * * *

### រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេច **នរោត្តម សីហនុវរ្ម័ន** ព្រះចៅ ក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញលិខិតលេខ ២៣០៥ / ៩៧ ករអក ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងលិខិតលេខ ៨២១ លេអ.ស ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩៧ របស់សាលាក្រុងភ្នំពេញ

-យោងពាក្យស្នើរបស់ក្រុមហ៊ុន មែកណេតធ៌ ហ្វ៊ុតវែរ ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៩៨

### សំរេច

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន មែកណេតធ៌ ហ្វ៊ុតវែរ ( MAGNATE FOOTWEAR Co., LTD) តំណាងដោយលោក TANG, CHAO- TUNG សញ្ជាតិចិន (តៃវ៉ាន់) ភេទប្រុស អាយុ ៥២ ឆ្នាំ អាសយដ្ឋាន 222 – SEC . 1 CHIA TUNG R.D, TATSUN TSUN. TATSUN HSIANG , CHANG HUA HSIEN , TAIWAN R . O . C កាន់លិខិតឆ្លងដែនលេខ M 1331676 ចុះថ្ងៃទី 15.01.1997 បង្កើត “ រោងចក្រផលិតស្បែកជើង នាំចេញ ” ដែលមានឈ្មោះថា ” មែកណេតធ៌ ហ្វ៊ុតវែរ ” មានទីតាំង ភូមិជង្រុក សង្កាត់ត្រពាំង ក្រសាំង ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

ប្រការ ២ : ការសាងសង់ និងរៀបចំគ្រឿងចក្រ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អោយបានសំរេចក្នុងរយៈពេល ០៣ ខែ ដោយរាប់បញ្ចូលទាំងរយៈពេលដំណើរការសាកល្បងផង ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និង គុណភាពផលិតផលហើយត្រូវធ្វើរបាយការណ៍ប្រចាំខែជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយ " ផលិតស្បែកជើង " ទៅតាមគំរូដែលតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៥ : រាល់ការនាំចេញផលិតផលសំរេចត្រូវមានវិញ្ញាបនបត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៦ : ក្រុមហ៊ុនត្រូវលើកបង្ហាញ " ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួននៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ ៧ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរ នឹងប្រការណាមួយដែលបានចែងខាងលើប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៨ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និង ប្រធានក្រុមហ៊ុន មេកណេតធ ហ្វូតវែរ ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ ៩ : ប្រកាសនេះមានអានុភាព អតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

អ៊ិត ប្រាំង

******

# ៤-ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

## ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៩

## ប្រកាសលេខ ០៩៩/៩៨/ពម.ប្រក

## ស្តីពីការតែងតាំងមន្ត្រីរាជការ

******

## រដ្ឋមន្ត្រីក្រសួងពត៌មាន

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស / ៩៨ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម នស / រកម / ០១៩៦ / ១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន

-យោងតាមសំណើរបស់អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា

-ពិនិត្យមើលលក្ខណៈសម្បត្តិ និងសមត្ថភាព មន្ត្រីរាជការ

**សំរេច**

ប្រការ ១ ៖ តែងតាំងលោក ឆោ អ៊ានរ៉ន ជាអនុប្រធាននាយកដ្ឋានបច្ចេកទេសអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា នៃក្រសួងព័ត៌មាន ។

ប្រការ ២ ៖ ឯកឧត្តមអគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ ឯកឧត្តមអគ្គនាយកទូរទស្សន៍ជាតិកម្ពុជា លោកប្រធាននាយកដ្ឋានបុគ្គលិក លោកប្រធាននាយកដ្ឋានផែនការ គណនេយ្យ ហិរញ្ញវត្ថុ និង សាមីខ្លួនត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ខៀវ កាញារីទ្ធ

*****

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៨

**ប្រកាសលេខ ១០០/៩៨/ពមប្រក**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

******

**រដ្ឋមន្ត្រីក្រសួងព័ត៌មាន**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម នស / រកម / ០១៩៦ / ១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងព័ត៌មាន

-យោងតាមសំណើរបស់អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា

-ពិនិត្យមើលលក្ខណៈសម្បត្តិ និងសមត្ថភាព មន្ត្រីរាជការ

**សំរេច**

**ប្រការ ១ :** តែងតាំងលោកស្រី សន មារីដា ជាអនុប្រធាននាយកដ្ឋានរដ្ឋបាលនៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា នៃក្រសួងពត៌មាន ។

**ប្រការ ២ :** ឯកឧត្តមអគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ ឯកឧត្តមអគ្គនាយក ទូរទស្សន៍ជាតិកម្ពុជា លោកប្រធាននាយកដ្ឋានបុគ្គលិក លោកប្រធាននាយកដ្ឋានផែនការ គណនេយ្យហិរញ្ញកិច្ច និង សាមីខ្លួនត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី
ស្តីទីអោធិការ
ហត្ថលេខា និងត្រា
**ខៀវ កាញារីទ្ធ**

******

## ៥-នីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**ប្រកាស**

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៩៩

**ប្រកាសលេខ ៣៥៧ អយក.ប្រក**

**ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅជីវ ផែនដីវិទ្យា**

**" សំរាប់សិស្សថ្នាក់ទី ៩ "**

******

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០១៩៩ / ៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ០៥៩៧ / ១៨៧ ចុះថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានពិនិត្យលិខិតឧទ្ទេសនាម លេខ ៣១៨ អយក.ឧទន ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំ យុវជន និង កីឡា ស្តីពីការបង្កើតគណៈកម្មការកែលំអ ប្រព័ន្ធអប់រំ

-បានពិនិត្យរបាយការណ៍របស់គណៈកម្មការ ពិនិត្យខ្លឹមសារសៀវភៅជីវ ផែនដីវិទ្យា សំរាប់ សិស្សថ្នាក់ទី ៩ ចុះថ្ងៃទី ១០ខែ មីនា ឆ្នាំ ១៩៩៩

**សំរេច**

**ប្រការ ១ :** អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅជីវ ផែនដីវិទ្យាសំរាប់សិស្សថ្នាក់ទី ៩ ដែលជាស្នាដៃនិពន្ធ របស់គណៈកម្មការវិទ្យាសាស្ត្រមធ្យមសិក្សា នៃវិទ្យាស្ថានស្រាវជ្រាវក្រសួងអប់រំ យុវជន និង កីឡា និងរៀបរៀងដោយ អ្នកស្រី ឆាន សោភ័ណ និង កញ្ញា អ៊ុំ ទ័ន្ទី ដើម្បីប្រើប្រាស់នៅតាមសាលារៀនចំណេះទូទៅ ។

**ប្រការ ២ :** អគ្គនាយកដ្ឋានបច្ចេកទេស នាយកដ្ឋានផែនការហិរញ្ញកិច្ច វិទ្យាស្ថានស្រាវជ្រាវ គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ អង្គភាពលក់ចែកផ្សាយ មណ្ឌលសម្ភារ នាយកដ្ឋានចំណេះទូទៅ និង មន្ទីរប្រសិក្សាធិការ មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ពេញលេខា និងត្រា

គា. សាហន

******

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៩៩

## ប្រកាសលេខ ៣៦២ អយក.ប្រក
## ស្តីពីការបើកសាលាបឋមសិក្សា ឯកជន ខ្មែរ ចិន ក្វាង សៀវ

* * * *

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០១៩៤ / ៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាលេខ នស / រកត / ០៧៩៦ / ៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ ឆ្នាំ

-បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ០៩៩៧ / ១៥៧ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ១៩៩៥ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញលិខិតស្នើសុំរបស់លោក ថៃ រ៉ាន់ ប្រធានសមាគមចិន កន្លាង ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដោយចំណារផ្តល់យោបល់របស់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ភ្នំពេញ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៨

-តាមយោបល់ឯកភាពរបស់ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១ :** អនុញ្ញាតអោយលោក ថៃ រ៉ាន់ បើកសាលាបឋមសិក្សាឯកជនខ្មែរ ចិន ក្វាង ស្ងៀវ ដែលមានទីតាំងស្ថិតនៅផ្ទះលេខ ៣១ ផ្លូវ ១៥៨ សង្កាត់ផ្សារដេប៉ូ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ចាប់ពីឆ្នាំសិក្សា ១៩៩៧- ៩៨នេះតទៅ ។

**ប្រការ ២ :** សាលាបឋមសិក្សាឯកជនខ្មែរ ចិន ក្វាង ស្ងៀវ ត្រូវនៅក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងត្រូវអនុវត្តកម្មវិធីសិក្សា តាមការអនុញ្ញាតរបស់ ក្រសួងអប់រំ យុវជន និងកីឡា ។

**ប្រការ ៣ :** លោក ថៃ រ៉ាន់ ត្រូវដឹកនាំ គ្រប់គ្រង ចាត់តាំងគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន ដែលមានសមត្ថភាពគរុកោសល្យសមស្រប ព្រមទាំងអនុវត្តអោយបានត្រឹមត្រូវតាមការ ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**ប្រការ ៤ :** ប្រធានមន្ទីរ ក្រសួងអប់រំ យុវជន និងកីឡា លោកប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យ-សិក្សា លោកប្រធាននាយកដ្ឋានចាត់តាំង លោកប្រធាននាយកដ្ឋានផែនការ ហិរញ្ញកិច្ច លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ លោកប្រធានការិយាល័យអប់រំ យុវជន និងកីឡាខណ្ឌទួលគោក នាយកសាលាបឋមសិក្សាឯកជនខ្មែរ ចិន ក្វាង ស្ងៀវ និងលោក ថៃ រ៉ាន់ មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

**គា សាខន**